ក្រសួងសុខាភិបាល | អង្គការសុខភាពពិភពលោក

# សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនិងអង្គការសុខភាពពិភពលោក

**សេចក្តីអំពីរឿងៈ** ប្រទេសកម្ពុជាពុំទាន់ទទួលការឆ្លងជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) ទេ!

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យតំណាងអង្គការសុខភាពពិភពលោកប្រចាំប្រទេសកម្ពុជាសូមបញ្ជាក់ថា **ប្រទេសកម្ពុជាពុំទាន់ទទួលរងការវាយប្រហារដោយការឆ្លងនៃជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ** (SARS) **ទេ។**

មានសេចក្តីរាយការណ៍នាពេលថ្មីៗនេះតាមរយៈប្រពន្ធ័ផ្សព្វផ្សាយបរទេសនិងក្នុងស្រុកថា ជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) បានរាលដាលមកដល់ប្រទេសកម្ពុជាហើយ។ មានរបាយការណ៍មួយបានព្យាយាមភ្ជាប់ករណីស្លាប់មួយដែលបណ្តាលមកពីជំងឺរលាកផ្លូវដង្ហើម ហើយដែលកើតឡើងនាខែមិនាកន្លងទៅនេះនៅក្នុងខេត្តរតនៈគីរីដែលជាខេត្តស្ថិតនៅភូមិភាគឦសាននៃប្រទេសកម្ពុជាទៅនឹងជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS)។ ក្រសួងសុខាភិបាលនិងអង្គការសុខភាពពិភពលោកសូមជំរាបជូនសាធារណៈជនឱ្យបានជ្រាបថា ពុំមានអាថ៌កំបាំងអ្វីនៅក្នុងជំងឺនេះទេ។ ករណីស្លាប់ខាងលើគឺជាការករណីនៃជំងឺផ្លូវដង្ហើមដែលបង្កដោយបាក់តេរី។ អ្នកជំងឺស្ទើរតែទាំងអស់បានជាសះស្បើយយ៉ាងឆាប់រហ័សក្រោមការព្យាបាលដោយអង់ទិប៊ីយ៉ូទិក ដែលបានផ្តល់ដោយបុគ្គលិកប៉ុស្តិ៍សុខភាពរបស់ក្រសួងសុខាភិបាល ដែលបំរើនិងផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋរស់នៅក្នុងភូមិទាំងពីរដែលមានករណីឈឺនោះ។ ពុំមានការចំលងជំងឺនេះទៅបុគ្គលិកសុខាភិបាលដែលព្យាបាលអ្នកភូមិដែលឈឺទាំងនោះទេ។ ប្រជាពលរដ្ឋរស់នៅក្នុងភូមិទាំងពីរនោះមានស្ថានភាពសុខភាពជាទូទៅទាបបំផុត ដោយប្រជាពលរដ្ឋភាគច្រើនមានកង្វះអាហារូបត្ថម្ភ ហើយរងគ្រោះដោយសារជំងឺរ៉ាំរ៉ៃដូចជារបេងនិងគ្រុនចាញ់។ នៅក្នុងលក្ខខណ្ឌបែបនេះរួមនឹងគ្មានការព្យាបាលសមស្របត្រឹមត្រូវនិងទាន់ពេលវេលា អ្នកជំងឺងាយនឹងរងគ្រោះថ្នាក់ដល់ជីវិតដោយសារតែជំងឺរលាកផ្លូវដង្ហើមសម្ញណាមួយ។ ដូច្នេះពុំមានការរាតត្បាតនៃជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) នៅខេត្តរតនគីរី ឬនៅក្នុងប្រទេសកម្ពុជាទេ។

គ្រុនក្តៅនិងក្អក គឺជាសញ្ញាដែលជាញឹកញាប់ជំរុញឱ្យមនុស្សរាប់លាននាក់លើពិភពលោកស្វែងរកការថែទាំសុខភាព។ ជាច្រើនទសវត្សមកហើយ ជំងឺរលាកផ្លូវដង្ហើមស្រួចជាពិសេសជំងឺរលាកសួត គឺជាមូលហេតុនាំមុខគេនៃមរណភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសក្នុងចំណោមកុមារនិងអ្នកដែលមានកង្វះអាហារូបត្ថម្ភ

និងអ្នកដ៏ទៃទៀតដែលមានកំលាំងទន់ខ្សោយ ។ ជាឧទាហរណ៏ ជំងឺរលាកផ្លូវដង្ហើមធម្មតាត្រូវបានគេប្រមាណថាបានសំលាប់កុមារជាង ១១,000 នាក់ជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា ។

ប្រសិនបើជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) នេះបានវាយប្រហារលើដល់ប្រទេសកម្ពុជា វាអាចបង្កឡើងជាការគំរាមកំហែងគួរឱ្យកត់សំគាល់ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសនេះ ហើយមិនមែនគ្រាន់តែប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ តែវាមានការប៉ះពាល់ផងដែរដល់ការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេផងដែរ ។ ការរាតត្បាតនៃជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) ក្នុងប្រទេសដ៏ទៃទៀតធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់វិស័យសេដ្ឋកិច្ចនៃតំបន់ទាំងមូល ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងអង្គការសុខភាពពិភពលោកបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការគំរាមកំហែងនេះ ហើយរាល់ពាក្យចចាមអារ៉ាមអំពីសក្តានុពលនៃករណីជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) នេះនៅក្នុងប្រទេស នឹងត្រូវបានធ្វើការស៊ើបអង្កេត វិធានការណ៏ក្នុងការការពារការឆ្លងជំងឺនៅក្នុងមន្ទីរពេទ្យដែលត្រូវបានជ្រើសរើសចំនួនពីរត្រូវបានពង្រឹង ហើយជាភព្វ័សំណាងល្អ រាល់ករណីសង្ស័យនិងករណីដែលបានអង្កេតត្រូវបានកំណត់ថាមិនមែនជាករណីជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) នេះទេ ។ ដូច្នេះ ប្រទេសកម្ពុជាស្ថិតនៅក្រៅការរាតត្បាតនៃជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) នៅឡើយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាន់យកឥរិយាបទបើកចំហរគ្មានការលាក់លៀម និងត្រៀមខ្លួនជាស្រេច ។ សាធារណៈជនទាំងអស់កំពុងតែទទួលបាននូវការផ្តល់ពតិមានជាទៀងទាត់ នូវរាល់ការវិវត្តិន៍ថ្មីៗអំពីជំងឺផ្លូវដង្ហើមស្រួចធ្ងន់ធ្ងរ (SARS) នេះ ។ ការផ្សព្វផ្សាយពតិមានមិនពិតរបស់ប្រពន្ធ័ផ្សព្វផ្សាយមិនត្រឹមតែមិនបានជួយជ្រោមជ្រែងតែប៉ុណ្ណោះទេ តែនៅបង្កភាពតក់ស្លុតនិងចលាចលថែមទៀតផង ។